ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Feb-2012, 15:46
CMS/CFO: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ការសុំការអនុញ្ញាតរបស់សហព្រះរាជអាជ្ញា ដើម្បីឆ្លើយតប និងការឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ទាក់ទិននឹងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃ ការជំនុំជម្រះសំណុំរឿង ០០២/១

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

| | |
|---|---|
| Elisabeth SIMONNEAU FORT | លោក គង់ សំអុន |
| | លោក Arthur VERCKEN |
| | លោក Jacques VERGÈS |

# ការសុំការអនុញ្ញាតដើម្បីឆ្លើយតប

១- សហព្រះរាជអាជ្ញាសុំការអនុញ្ញាតដើម្បីឆ្លើយទៅនឹង "ចម្លើយតបរបស់ អៀង សារី ទៅនឹង សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/១" ("សំណើ")[1]។ ដើម្បីប្រសិទ្ធិភាព ការឆ្លើយតបជាសារធាតុត្រូវបានកំណត់ដូចខាងក្រោម។ ការឆ្លើយតបមួយ គឺជាការចាំបាច់ ដោយសារមានការបកស្រាយខុសយ៉ាងធ្ងន់ធ្ងរមួយដោយមេធាវីការពារក្តី ដែលបើសិនជាយើងទុកឲ្យដូច្នេះ អាចនាំឲ្យអង្គជំនុំជម្រះយល់ច្រឡំ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា វាជាផលប្រយោជន៍នៃយុត្តិធម៌ដែលអនុញ្ញាតឲ្យមានការដាក់ការឆ្លើយតបដោយសង្ខេបនេះ។

# ការឆ្លើយតប

២- នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើមួយជូនអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") សុំឲ្យពិចារណាអំពី ការពង្រីកវិសាលភាពនៃកិច្ចដំណើរការនីតិវិធីសវនាការជំនុំជម្រះក្នុងសំណុំរឿង ០០២/១ ដើម្បីបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមចំនួនបី: ស្រុក១២ ទួលពោធិ៍ជ្រៃ និង ស-២១ ("សំណើ")[2]។ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ មេធាវីការពារក្តី អៀង សារី ("មេធាវីការពារក្តី") បានដាក់ចម្លើយតបប្រញាប់ប្រញាល់មួយ ដោយស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង បដិសេធចោលដោយសង្ខេបទៅនឹងសំណើនេះ ថាជាផ្នែកនៃ "លំនាំនៃសេចក្តីសន្និដ្ឋានគ្មានមូលដ្ឋានទាំងមូល"[3] ដែលមានតម្លៃស្មើនឹង "ការរំលោភបំពានដំណើរការ" មួយ[4]។ មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះដាក់សហព្រះរាជអាជ្ញាក្រោម "វិធានការដាស់តឿននានា"[5] ដែលគេមិនបានបញ្ជាក់ ដើម្បីឲ្យប្រាកដថា សហព្រះរាជអាជ្ញា "បញ្ឈប់និងបញ្ចប់លែងឲ្យមាន"[6] ការអនុវត្តនៃការដាក់សេចក្តីសន្និដ្ឋានដែលមេធាវីការពារក្តីថាមានចរិកលក្ខណៈជា សំណើឲ្យមានការពិចារណាឡើងវិញទៅលើដីកាសម្រេច

---

[1] **E163/1** ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃសវនាការជំនុំជម្រះសំណុំរឿង ០០២/១, ៣ កុម្ភៈ ២០១២។

[2] **E163** សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃសវនាការជំនុំជម្រះ, ២៧ មករា ២០១២។

[3] **E163/1** ត្រង់ទំព័រទី១។

[4] **E163/1** *ដដែលដូចខាងលើ*។

[5] **E163/1** *ដដែលដូចខាងលើ*។

[6] **E163/1** *ដដែលដូចខាងលើ*។

បំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ[7] ("ចម្លើយតប")។ គ្មានក្រុមមេធាវីការពារក្តីផ្សេងបាន ដាក់ចម្លើយតបជូនអង្គជំនុំជម្រះទេ។

៣- ចម្លើយតបនេះទាំងមូលគឺគ្មានអង្គសេចក្តីទេ។ ចម្លើយតបពឹងផ្អែកទៅលើការសន្មតថា សំណើស្វែងរក ឲ្យមានការពិចារណាឡើងវិញ ចំពោះដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។ នេះគឺជាការ យល់ខុស។ សំណើស្ថិតក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ និងគោលការណ៍ ណែនាំជាបន្តបន្ទាប់ដែលបានផ្តល់ជូនដោយ និងក្នុងនាមអង្គជំនុំជម្រះ

*អង្គជំនុំជម្រះកត់សម្គាល់នូវ ការចង្អុលបង្ហាញរបស់សហព្រះរាជអាជ្ញានៅក្នុងសំណើសុំរបស់ ខ្លួនអំពីបញ្ហាបន្ថែមដែលអាចមាន សម្រាប់ដាក់បញ្ចូលនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូង ហើយអង្គជំនុំជម្រះត្រូវបានណែនាំ ដោយការយល់ឃើញរបស់សហព្រះរាជអាជ្ញាថាជាការចោទ ប្រកាន់ជាអាទិភាព សម្រាប់ធ្វើការពិចារណាក្នុងអំឡុងដំណាក់កាលនៃការជំនុំជម្រះក្រោយៗ ទៀត...*[8]។

៤- ដូចសហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋានពីដើមដំបូងនៃសំណុំរឿង ០០២/១ យ៉ាងដូច្នេះថា:

*សហព្រះរាជអាជ្ញា គាំទ្រពេញទំហឹងចំពោះតម្រូវការនៃការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំ រឿង ០០២ និងគោរពតាមសិទ្ធិអំណាចរបស់អង្គជំនុំជម្រះ ដើម្បីចេញដីកាសម្រេចបំបែកកិច្ចដំណើរ ការនីតិវិធី ក្នុងផលប្រយោជន៍នៃយុត្តិធម៌ និងថាបើមិនដូច្នោះទេ អាចគ្រប់គ្រងការបែងចែក ចែកពេលវេលា និងធនធានផ្សេងៗនៅពេលសវនាការជំនុំជម្រះ*[9]។

---

[7] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួន២,* ២២ កញ្ញា ២០១១ ("ដីកាសម្រេចបំបែកកិច្ចដំណើរការ នីតិវិធី"។

[8] **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញនៃពាក្យពេចន៍ក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការ នីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (E124/2) និងញត្តិស្នើសុំ និងឧបសម្ព័ន្ធនានាដែលពាក់ព័ន្ធ, ១៨ តុលា ២០១១ ត្រង់កថាខណ្ឌទី១២។ ជំហររបស់អង្គជំនុំជម្រះត្រូវបានបញ្ជាក់អះអាងឡើងវិញនៅឯកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ ដែលនៅពេលនោះ តំណាងមេធាវីការពារក្តីមានវត្តមាន។ ប្រភពទាំងនេះត្រូវបានដាក់បញ្ចូលក្នុងសំណើដើម ត្រង់កថាខណ្ឌទី១-៣។

[9] **E124/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីសំណើសុំឲ្យមានការពិចារណាឡើងវិញចំពោះពាក្យពេចន៍នៃ "ដីកាសម្រេចបំបែក កិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួន២*", ២៣ កញ្ញា ២០១១, ត្រង់កថាខណ្ឌទី៤។

៥- ការសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យ អង្គជំនុំជម្រះគួរដាក់ "វិធានការដាស់តឿន" លើសហព្រះរាជអាជ្ញាតាមការចោទប្រកាន់ថា "រំលោភបំពានដំណើរការ" នោះ ពឹងផ្អែកទៅលើអំណះអំណាងដែលបានដកស្រង់*តាមពាក្យត្រង់និមួយៗ* ប៉ុន្តែមិនបានដកស្រង់ ឬកំណត់តាមសេចក្តីសន្និដ្ឋានផ្ទាល់របស់សហព្រះរាជអាជ្ញាជូនអង្គជំនុំជម្រះតុលាការកំពូល ក្នុងការឆ្លើយតបទៅនឹងលំនាំមួយនៃបណ្តឹងសាទុក្ខ ដែលគេមិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែតដែលបានដាក់ដោយក្រុមមេធាវីការពារក្តីនោះទេ:

> *លំនាំនៃសេចក្តីសន្និដ្ឋានដែលគ្មានមូលដ្ឋានទាំងមូលនេះបានរំលោភចំពោះដំណើរការរបស់អ.វ.ត.ក និងជាបន្ទុកនៃធនធាន និងពេលវេលាដ៏ក្រខ្សត់របស់ អង្គជំនុំជម្រះ ក៏ដូចជារបស់គូភាគីនានា*[10] ។

៦- នៅក្នុងបរិបទនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ចេតនាពិត ភាពមិនសមតាមតក្កភាព និងការឥតគួរសមនៃចម្លើយតប - ដែលវាគ្រាន់តែជាការ*ឆ្លើយដាក់អ្នកផ្សេង* - បានក្លាយទៅជារឿងមួយច្បាស់ជាក់ស្តែងរួចទៅហើយ។ ទាក់ទិននឹងចំណុចនេះ សហព្រះរាជអាជ្ញាកត់សំគាល់ឃើញថា វិធានស្តីពីទង្វើឥរិយាបថ និងក្រមសីលធម៌ បានចងកាតព្វកិច្ចចំពោះមេធាវីការពារក្តីដែលបានទទួលឲ្យចូលក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហាមឃាត់ជាដាច់ខាតចំពោះ "ទង្វើរំខាន"[11] នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់អាណត្តិ "ក្នុងស្មារតីនៃសហភាតរភាព ភាពសមរម្យ និងការគួរសម"[12] នៅក្នុងការធ្វើអន្តរទំនាក់ទំនងរវាងមេធាវី។ *វិធានស្តីពីក្រមសីលធម៌វិជ្ជាជីវៈ* របស់តុលាការកំពូល អាឡាស្កា គឺមានភាពច្បាស់លាស់ជាង:

> *មេធាវីការពារក្តីមិនត្រូវធ្វើបណ្តឹង ឬការពារបណ្តឹងណាមួយ(តាមផ្លូវតុលាការ) ឬពោលអះអាង ឬតវ៉ាប្រឆាំងនឹងបញ្ហាអ្វីមួយដែលនៅក្នុងនោះទេ លុះត្រាតែមានមូលដ្ឋានណាមួយខាងអង្គច្បាប់និងខាងអង្គហេតុគ្រប់តាមលក្ខណៈច្បាប់ដែលឲ្យធ្វើដូច្នេះបាន...*[13]

---

[10] ត្រង់ទំព័រទី១ នៃចម្លើយតប, មេធាវីការពារក្តីដកស្រង់ដោយផ្ទាល់ ប៉ុន្តែគ្មានការសន្ទតពីឯកសារ **E130/4/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឲ្យជនជាប់ចោទមានវត្តមានដោយផ្ទាល់ខ្លួនដើម្បីស្តាប់នូវបទចោទ និងសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់, ១២ មករា ២០១២ ត្រង់កថាខ័ណ្ឌទី១១ និងឯកសារ **E154/1/12** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសំណើរបស់គាត់សុំឲ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនរក្សាការប្រាស្រ័យទំនាក់ទំនងការងារដោយចំហរ និងដោយតម្លាភាព ជាមួយគូភាគីទាំងអស់, ១ កុម្ភៈ ២០១២, ត្រង់កថាខ័ណ្ឌទី១១។

[11] ក្រមសីលធម៌នៃមេធាវី ដែលបានចុះក្នុងបញ្ជីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា, មាត្រា២៤។

[12] *ដដែលដូចខាងលើ,* មាត្រា២៥។

[13] វិធាននៃក្រមសីលធម៌វិជ្ជាជីវៈនៃរដ្ឋ Alaska (Alaska Rules of Professional Conduct) (ឆ្នាំ២០១១-២០១២), SCO 1680, វិធាន៣.១។

*ភារកិច្ចរបស់មេធាវីក្នុងការធ្វើសកម្មភាពប្រកបដោយការយកចិត្តទុកដាក់ដោយសមហេតុសមផល គឺមិនតម្រូវឱ្យប្រើប្រាស់នូវយុទ្ធវិធីវាយលុកប្បច្រានចោលជាមុននូវការប្រព្រឹត្តចំពោះរាល់បុគ្គលទាំងអស់ដែលពាក់ព័ន្ធនៅក្នុងដំណើរការនៃរឿងក្តីដោយការគួរសម និងសេចក្តីគោរពនោះឡើយ*[14] ។

៧- សហព្រះរាជអាជ្ញា សូមជូនជាសេចក្តីសន្និដ្ឋានថា ការយកមកប្រើប្រាស់ដោយចេតនានូវសេចក្តីយោងដែលត្រូវបានចាត់ទុកថាមិនមាននៅក្នុងសារណានានារបស់ភាគីផ្សេងៗទៀត និងការដាក់នូវសារណាទាំងឡាយដោយគ្មានការវែកញែកហេតុផល និងមិនគ្រប់តាមលក្ខណៈច្បាប់ គឺជាការខកខានមិនបានបំពេញគ្រប់ទៅតាមបទដ្ឋាននៃក្រមសីលធម៌ដែលមេធាវីការពារក្តីរបស់ អៀង សារី កំពុងប្រតិបត្តិតាម។

## ដំណោះស្រាយដែលស្នើសុំ

៨- អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមបញ្ជាក់ជូនសារជាថ្មីឡើងវិញនូវសំណើរបស់ខ្លួនដែលសុំឱ្យអង្គជំនុំជម្រះយល់ព្រមយកតាមសំណើដូចដែលបានដាក់ជូននេះ និងសូមឱ្យសំរេចថា ការពង្រីកវិសាលភាពនៃសវនាការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ ០០២/១ គឺដើម្បីបានជាផលប្រយោជន៍ដល់យុត្តិធម៌ ហើយសូមឱ្យចេញដីកាសំរេចថា ទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ទាំងឡាយដូចខាងក្រោមនេះដែលមកពីក្នុងដីកាដំណោះស្រាយ គួរបានយកមកដាក់ឱ្យនៅក្នុងរង្វង់នៃវិសាលភាពនៃសំណុំរឿងលេខ ០០២/១៖

(ក) ការសម្លាប់អ្នកជម្លៀស ១៧ មេសា ១៩៧៥ នៅទីតាំងក្នុងកំពង់ត្រឡាចលើ (ស្រុក១២) ខេត្តកំពង់ឆ្នាំង (តំបន់៣១ នៃភូមិភាគបស្ចិម) (កថាខ័ណ្ឌទី៦៩១, ៦៩៣-៦៩៧ នៃដីកាដំណោះស្រាយ)។

(ខ) ការសម្លាប់អតីតពួកទាហាន និងមន្ត្រីរបស់របប លន់ នល់ ក្នុងឆ្នាំ១៩៧៥ ទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ (តំបន់៧ នៃភូមិភាពាយ័ព្យ) (កថាខ័ណ្ឌទី៦៩៨-៧១១ នៃដីកាដំណោះស្រាយ ។ និង

[14] *ដូចគ្នានឹងខាងលើ* វិធាន១.៣ , សេចក្តីអធិប្បាយផ្តល់មតិទី១។

(គ) មន្ទីរសន្តិសុខស-២១ និងទីតាំងសម្លាប់មនុស្សដែលពាក់ព័ន្ធនៅជើងឯក ខេត្តកណ្ដាល (កថាខ័ណ្ឌទី៤១៥-៤៧៥ នៃដីកាដំណោះស្រាយ) *រួមទាំង* ការបោសសម្អាតកម្មាភិបាល មកពីភូមិភាគឧត្តរថ្មី ភូមិភាគកណ្ដាល(ភូមិភាគឧត្តរចាស់) និងភូមិភាគបូព៌ា ដែលបាន បញ្ជូនទៅមន្ទីរស-២១ (កថាខ័ណ្ឌទី១៩២-២០៤ នៃដីកាដំណោះស្រាយ) ប៉ុន្តែ *មិនរាប់បញ្ចូល* ការដ្ឋានព្រៃស ក្នុងស្រុកដង្កោរ ខេត្តកណ្ដាលទេ។

៩- សហព្រះរាជអាជ្ញា ក៏សូមស្នើផងដែរឲ្យអង្គជំនុំជម្រះធ្វើការព្រមានដល់មេធាវីការពារក្ដីរបស់ អៀង សារី ទាក់ទងនឹងភារកិច្ចរបស់ពួកគេក្នុងការប្រព្រឹត្តត្រឹមត្រូវ ព្រមទាំងមានការគួរសមចំពោះភាគីដទៃ ទៀត និងចំពោះការអនុវត្តមិនត្រឹមត្រូវក្នុងការធ្វើសារណាផ្សេងៗដែលមិនត្រូវតាមលក្ខណៈច្បាប់៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |